# តំបន់សេដ្ឋកិច្ចពិសេស ជាឧបករណ៍សម្រាប់ពន្លឿនកំណើនសេដ្ឋកិច្ច៖ ការសិក្សាលើឯកសារ

## ទស្សនទាន និងនិយមន័យ

តំបន់សេដ្ឋកិច្ចពិសេស (SEZs) កើតមានជាយូរមកហើយក្នុងទម្រង់ផ្សេងៗ ប៉ុន្តែចាប់ពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ទើបគេប្រើវាដោយចេតនា ធ្វើជាឧបករណ៍ផ្នែកគោលនយោបាយ។ សហរដ្ឋអាមេរិកបានបង្កើត SEZs ទី១ របស់ខ្លួននៅក្រុងញ៉ូយ៉កក្នុងឆ្នាំ១៩៣៧ បន្ទាប់មកក្នុងឆ្នាំ១៩៤២ បានកសាង SEZs នៅ កោះព័រតូរីកូ (Pakdeenurit, Suthikarnnarunai and Rattanawong 2014)។ ដោយឡែក តំបន់ឧស្សាហកម្មសេរីទំនើបទី១ ត្រូវបានផ្តួចផ្តើមនិងកសាងឡើងនៅក្រុង Shannon ប្រទេសអៀរឡង់ ក្នុងឆ្នាំ១៩៥៩ (Farole and Akinci 2011)។ ចាប់ពីទសវត្សរ៍១៩៦០ មក SEZs បានក្លាយជាសមាសភាគដ៏សំខាន់នៃ យុទ្ធសាស្ត្រសេដ្ឋកិច្ចនិងឧស្សាហកម្មជាតិ ក្នុងទូទាំងពិភពលោក ជាពិសេសនៅ អាស៊ីខាងកើត និង អាមេរិកឡាទីន។ ឧទាហរណ៍ ប្រទេសកូឡុំប៊ីបានបង្កើតតំបន់ទី១ របស់ខ្លួនឈ្មោះថា Barranquilla ក្នុងឆ្នាំ១៩៦៤។ មួយឆ្នាំក្រោយមក សាធារណរដ្ឋដូមីនីក បានដើរតាមប្រទេសកូឡុំប៊ី ដោយបង្កើតតំបន់ La Romana ក្នុងឆ្នាំ១៩៦៥ (Farole 2011)។ នៅអាស៊ី ប្រទេសឥណ្ឌាបានបង្កើត SEZs ទី១ របស់ខ្លួនក្នុងឆ្នាំ១៩៦៥ តៃវ៉ាន់បានបង្កើតវាក្នុងឆ្នាំ១៩៦៦ កូរ៉េខាងត្បូងបានបង្កើតក្នុងឆ្នាំ១៩៧០ ហើយ ចិនបានបង្កើតក្នុងឆ្នាំ១៩៨០ (Farole 2011)។ ខណៈដែល សហរដ្ឋអាមេរិកជាអ្នកនាំមុខគេលើ SEZs ទំនើប ឥណ្ឌាមាន SEZs ច្រើនជាងគេ ហើយ SEZs នៅចិន ត្រូវបានចាត់ទុកថាមានជោគជ័យខ្លាំងបំផុត ជាពិសេសនៅក្រុង Shenzhen។ ជោគជ័យនៃ SEZs នៅចិន បានទាក់ទាញចំណាប់អារម្មណ៍ច្រើនណាស់ពីសំណាក់អ្នកសិក្សាស្រាវជ្រាវ អ្នកកសាងគោលនយោបាយ និងអ្នកអភិវឌ្ឍឧស្សាហកម្ម ទូទាំងពិភពលោក។ មកទល់សព្វថ្ងៃ SEZs ផ្សេងៗ ដូចជា តំបន់ពាណិជ្ជកម្មសេរី តំបន់កែច្នៃសម្រាប់ការនាំចេញ ឧទ្យានឧស្សាហកម្ម កំពង់ផែសេរី និង តំបន់សហគ្រាស ជាដើម បណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានប្រើប្រាស់វា ដើម្បីពន្លឿនការនាំចេញ ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស(FDI) និងធ្វើឧស្សាហូបនីយកម្មសេដ្ឋកិច្ច។

ពាក្យ SEZs មួយអាចនាំមកនូវ រូបភាពខុសៗគ្នាជាខ្លាំង ដូចជា៖ បណ្តុំឧស្សាហកម្មបិទជិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងពោរពេញទៅដោយបណ្តាក្រុមហ៊ុនពហុជាតិ ដែលអាចនឹងប្តូរទីតាំងផលិតយ៉ាងងាយស្រួល, "អព្ភូតហេតុសេដ្ឋកិច្ចនៃក្រុង Shenzhen" ដែលដើមឡើយជាភូមិនេសាទដាច់ស្រយាលហើយបានរីកលូតលាស់ជា ទីក្រុងមានសន្ទុះខ្លាំងបំផុតក្នុងពិភពលោក និងជារដ្ឋធានីនៃនវានុវត្តន៍នៅចិន, និងមជ្ឈមណ្ឌលឡូជីស្ទិក និងពាណិជ្ជកម្មលំដាប់ពិភពលោកនៅទីក្រុងឌូបៃ និងប្រទេសសិង្ហបុរី ជាដើម (Farole and Akinci 2011)។ ជារួម SEZs ភាគច្រើនតែងមានលក្ខណៈសំគាល់ដូចតទៅ៖ ១) តំបន់មានព្រំដែនកំណត់ច្បាស់ និងមានសន្តិសុខ ២) តំបន់គ្រប់គ្រងដោយអង្គភាពគ្រប់គ្រង ឬរដ្ឋបាលតែមួយ ៣) តំបន់មានផ្តល់ឧត្តមភាពទៅតាមទីតាំងរបស់ខ្លួន ៤) តំបន់ស្ថិតក្រោមរបបពន្ធគយពិសេស និងនីតិវិធីគេបានរៀបចំឲ្យសាមញ្ញឡើង (Shakya 2009)។ ក្នុងនេះ លក្ខណៈទី៤ ជាលក្ខណៈសំគាល់សំខាន់ជាងគេនៃ SEZ (Farole 2011) ពីព្រោះលក្ខណៈសំគាល់ឯទៀតវាខុសៗគ្នាខ្លាំងណាស់។ ផ្ទុយទៅវិញ គំរូ SEZ នៅចិន គេបានកំណត់ថាជា សកម្មភាព និងសេវាកម្មសេដ្ឋកិច្ចដែលជាប់ទាក់ទងគ្នាយ៉ាងស្មុគស្មាញ គឺមិនមែនជា អង្គភាពដែលមានមុខងារតែមួយនោះទេ។ ដូច្នេះហើយ SEZs នៅចិន តែងមានទំហំធំជាង និងបម្រើមុខងារច្រើនមុខជាង SEZs នៅប្រទេសផ្សេងទៀត (Wong 1987; Zeng 2010)។

Shah (2008, 4) បានកំណត់ SEZs ថាជា "តំបន់ភូមិសាស្ត្រមានបរិវេណជាក់លាក់នៅក្នុងប្រទេសនានា ពោលគឺ ផ្ទៃដីមានព្រំប្រទល់កំណត់ច្បាស់ ដែលគេប្រើប្រាស់ដើម្បីលើកទឹកចិត្តដល់ឧស្សាហកម្ម កម្មន្តសាលកម្ម និងសេវាកម្មផ្សេងៗសម្រាប់បម្រើការនាំចេញ ហើយតំបន់ទាំងនោះ ច្រើនតែអាចសំគាល់បានដោយសារមានគោលនយោបាយសេដ្ឋកិច្ច និងច្បាប់ពន្ធដារ ធូរទូលាយ"។ Farole (2011, 23) បានកំណត់និយមន័យ SEZs ស្រដៀងគ្នាដែរ ប៉ុន្តែសព្វគ្រប់ជាង ដូចខាងក្រោមនេះ៖

> តំបន់ភូមិសាស្ត្រ មានព្រំប្រទល់កំណត់ច្បាស់ស្ថិតក្នុងរង្វង់ព្រំដែនជាតិ របស់ប្រទេសមួយជាក់លាក់ ហើយតំបន់នោះមានវិធានច្បាប់ផ្នែកអាជីវកម្ម ខុសប្លែកពីវិធានច្បាប់ ដែលមានអនុវត្តជាទូទៅនៅក្នុងទឹកដីប្រទេសនោះ។ វិធានច្បាប់ខុសប្លែកគេទាំងនេះ ច្រើនពាក់ព័ន្ធទៅនឹង លក្ខខណ្ឌក្នុងការធ្វើវិនិយោគពាណិជ្ជកម្មអន្តរជាតិនិងបែបបទគយ ការយកពន្ធ និងក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ពោលគឺ គេផ្តល់ឲ្យតំបន់នោះនូវ បរិយាកាសអាជីវកម្មមួយដែលមានគោលនយោបាយធូរទូលាយជាង និងមានការគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាពជាង បើធៀបនឹងទឹកដីជាទូទៅរបស់ប្រទេសជាតិនោះ។

---

អត្ថបទនេះរៀបរៀងឡើងដោយ បណ្ឌិត វ៉ែន សីហា អ្នកស្រាវជ្រាវនៅផ្នែកសេដ្ឋកិច្ចនៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា Ven Seyhah. 2018. “Special Economic Zones as a Tool for Accelerating Economic Growth: A Literature Review.” *Cambodia Development Review* 22 (1): 7-11.

## ម៉ូដែលនៃតំបន់សេដ្ឋកិច្ចពិសេស

ម៉ូដែលនៃ SEZs មានច្រើនបែបច្រើនសណ្ឋាន ទៅតាមគោលដៅផ្នែកគោលនយោបាយ គោលគំនិតស្ដីពី SEZs និងយុទ្ធសាស្ត្របែងចែកប្រភេទ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ដូច្នេះហើយ ការធ្វើចំណាត់ថ្នាក់ SEZs ក៏ជួបការលំបាក។ ដោយផ្អែកលើរបៀបធ្វើចំណាត់ថ្នាក់ស្នើឡើងដោយ Akinci and Crittle (2008) និង Farole (2011), Farole and Akinci (2011) បានបែងចែក SEZs ជា ៥ម៉ូដែល ទៅតាម គោលដៅអភិវឌ្ឍន៍ ទំហំ ទីតាំង សកម្មភាព និង ទីផ្សារ គឺមាន តំបន់ជំនួញ/ពាណិជ្ជកម្មសេរី(FTZ) តំបន់កែច្នៃសម្រាប់ការនាំចេញបែបប្រពៃណី(EPZ) សហគ្រាសសេរី(FE)/EPZ មានតែមួយអង្គភាព EPZ បែបកូនកាត់ និងផែសេរី ដូចមានបញ្ជាក់សង្ខេបក្នុង តារាង១ ។

## តំបន់សេដ្ឋកិច្ចពិសេស ក្នុងលក្ខណៈជាឧបករណ៍ផ្នែកគោលនយោបាយ

ហេតុផលក្នុងការបង្កើត SEZs គឺការរំពឹងថា វាជួយពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច ដោយសម្រេចគោលដៅផ្នែកគោលនយោបាយបានលឿនជាងករណីគ្មានវា។ កន្លងមកគេតែងប្រើវាដើម្បីទាក់ទាញ វិនិយោគផ្ទាល់ពីបរទេស(FDI) កាត់បន្ថយភាពគ្មានការងារធ្វើ ជួយទ្រទ្រង់កំណែទម្រង់សេដ្ឋកិច្ច និង សាកល្បងយន្តការ និងវិធីសាស្ត្រផ្នែកគោលនយោបាយថ្មីៗ (Akinci and Crittle 2008; Farole 2011; Farole and Akinci 2011)។

***ការទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស៖*** កម្មវត្ថុចម្បងនៃ SEZs គឺទាក់ទាញវិនិយោគផ្ទាល់ពីបរទេស។ ចំណុចនេះសំខាន់ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះ SEZs ស្ទើរតែទាំងអស់ត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញវិនិយោគក្នុងវិស័យប្រើពលកម្មច្រើន និងផ្ដោតលើការនាំចេញដូចជា ផ្នែកកាត់ដេរសម្លៀកបំពាក់និងផលិតស្បែកជើង និងការផ្គុំតម្លើងគ្រឿងបង្គុំអេឡិចត្រូនិក និងយានយន្ត ជាដើម។

***ការកាត់បន្ថយភាពគ្មានការងារធ្វើ៖*** ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន មានពលករមានជំនាញទាប និងប្រៀវត្សរ៍ទាប ច្រើនណាស់ ហើយ SEZs អាចស្រូបយកកម្លាំងពលកម្មដ៏សម្បូរនេះ ដែលបើមិនដូច្នោះទេ នឹងត្រូវបម្រើការមិនអស់លទ្ធភាព ឬក៏គ្មានការងារធ្វើតែម្ដង។ SEZs នៅប្រទេសទុយនីស៊ី និងសាធារណរដ្ឋដូមីនីក គេតែងលើកជារឿយៗធ្វើជា ឧទាហរណ៍នៃ គំរូ SEZs ដែលបានជួយបង្កើតការងារជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃ។

តារាង១៖ លក្ខណៈសំគាល់នៃ SEZ បែបផ្សេងៗ

| | FTZ | EPZ | FE | EPZ កូនកាត់ | ផែសេរី |
|---|---|---|---|---|---|
| គោលដៅ | ទ្រទ្រង់ពាណិជ្ជកម្ម | ពន្លឿនការនាំចេញផលិតផលកម្មន្តសាល | ពន្លឿនការនាំចេញផលិតផលកម្មន្តសាល | ពន្លឿនការនាំចេញផលិតផល | ជម្រុញការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ដោយប្រមូលផ្ដុំធនធានសេដ្ឋកិច្ច |
| ទំហំ | <50 ហិកតា | <100 ហិកតា | តំបន់គ្មានកំណត់បរិវេណ | - ផ្នែកខ្លះកំណត់ថាជា EPZ បែបប្រពៃណី<br>- ផ្នែកខ្លះបើកចំហសម្រាប់ក្រុមហ៊ុនគ្រប់ប្រភេទ | ធំទូលាយ (ប្រភេទធំបំផុត) មានតំបន់លំនៅដ្ឋាន និងមជ្ឈមណ្ឌលដឹកជញ្ជូន (ឧ. ផែ, អាកាសយានដ្ឋាន) |
| ទីតាំង | ផែសមុទ្រ និងអាកាសយានដ្ឋាន | គ្មានទីតាំងរួមគ្នា | កន្លែងណាក៏បាន ឬក្នុងតំបន់កំណត់ | មិនពាក់ព័ន្ធ | មិនពាក់ព័ន្ធ |
| សកម្មភាព | - ដឹកឆ្លងកាត់<br>- ពាណិជ្ជកម្ម | - ការផលិតនិងកែច្នៃជាសំខាន់សម្រាប់នាំចេញ<br>- ខ្លះមានការកែសម្រួលដើម្បីអាចធ្វើសកម្មភាពច្រើនទៀត | សកម្មភាពផលិតនិងកែច្នៃបម្រើការនាំចេញ | - ការផលិតនិងកែច្នៃជាសំខាន់សម្រាប់នាំចេញ<br>- ខ្លះមានការកែសម្រួលដើម្បីអាចធ្វើសកម្មភាពច្រើនទៀត | គ្រប់សកម្មភាពសេដ្ឋកិច្ច |
| ទីផ្សារ | ក្នុងស្រុក, នាំចេញទៅវិញ | នាំចេញ | នាំចេញ | នាំចេញ, ក្នុងស្រុក | ក្នុងតំបន់ ក្នុងស្រុក, នាំចេញ |
| គំរូមួយចំនួន | Colón FTZ នៅប៉ាណាម៉ា (បើកឆ្នាំ១៩៤៨) | Masan FTZ នៅកូរ៉េខាងត្បូង (បើកឆ្នាំ១៩៧០) | ម៉ូរីស និង ម៉ិកស៊ិក | Lat Krabang នៅថៃ | Aqaba នៅហ្សកដានី SEZs នៅចិន |

Sources: Akinci and Crittle 2008; Farole 2011; Farole and Akinci 2011

តារាង២៖ លក្ខណៈសំគាល់ និងផលប៉ះពាល់នៃ SEZs ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ

| ដំណាក់កាលអភិវឌ្ឍន៍ | | ការចូលរួមចំណែករំពឹងទុក | |
|---|---|---|---|
| SEZ ជាកតាលីករ | ប្រទេសម្ចាស់ផ្ទះ | ឋិតិវន្ត | ថាមវន្ត |
| តំបន់ដោយឡែក | សេដ្ឋកិច្ចផ្អែកលើកសិកម្ម<br>ប្រទេសមានចំណូលទាប<br>ពលកម្មតម្លៃទាប មិនជំនាញ | FDI<br>ការងារ<br>កំណើននាំចេញ | |
| ការតភ្ជាប់ទៅនឹងសេដ្ឋកិច្ចក្នុងស្រុក | ប្រទេសមានចំណូលមធ្យម<br>ខ្សែសង្វាក់តម្លៃ/សហគ្រាសក្នុងស្រុករឹងមាំ<br>តម្លៃពលកម្មកើនឡើង<br>ពលកម្មជំនាញ ឬពាក់កណ្តាលជំនាញ | | ការបង្កើនកម្រិតជំនាញ<br>ការផ្ទេរបច្ចេកវិទ្យា<br>ពិពិធកម្មការនាំចេញ<br>បង្កើនប្រសិទ្ធភាពធ្វើជំនួញនៃ សហគ្រាសក្នុងស្រុក<br>កញ្ចុំឧស្សាហកម្ម<br>ការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល |
| សម្រួលការបង្កើតកញ្ចុំឧស្សាហកម្ម, នវានុវត្តន៍ និង SEZs ឯកទេស | សេដ្ឋកិច្ចឧស្សាហកម្ម | | ការបង្កើតកញ្ចុំឧស្សាហកម្ម<br>នវានុវត្តន៍ |

Source: adopted from Warr and Menon 2015

***ការជួយទ្រទ្រង់ យុទ្ធសាស្ត្រកែទម្រង់សេដ្ឋកិច្ចធំទូលាយ៖*** SEZs ជាយន្តការងាយស្រួលមួយដែលជួយឲ្យប្រទេសមួយចំនួនអាចធ្វើពិពិធកម្មទំនិញនាំចេញ និងកាត់បន្ថយរបាំងរារាំងការនាំចេញ ដោយអាចរក្សាទុកដដែលនូវវិធានការគាំពារផ្សេងៗទៀតនៅក្នុងប្រទេស។ SEZs នៅចិន កូរ៉េខាងត្បូង ម៉ូរីស និង តៃវ៉ាន់ សុទ្ធតែដើរតាមលំនាំនេះ។

***ការសាកល្បងយន្តការ និងវិធីសាស្ត្រថ្មីៗ ផ្នែកគោលនយោបាយ៖*** ចិនបានប្រើប្រាស់ SEZs ជាមន្ទីរពិសោធន៍សម្រាប់សាកល្បងគោលនយោបាយបើកចំហ និងកំណែទម្រង់សេដ្ឋកិច្ចរបស់ខ្លួនក្នុងទសវត្សរ៍១៩៨០ នៅពេលប្រទេសចិនកំពុងមានសេដ្ឋកិច្ចបិទទ្វារនៅឡើយ។ វិធីសាស្ត្រពិសោធន៍មើលនេះ គួបផ្សំនឹងផ្តត់គំនិតផ្តោតលើកំណែទម្រង់ផង ក៏ទទួលបានជោគជ័យខ្លាំងមែន។

## ការរីកចម្រើន និងចូលរួមចំណែកនៃតំបន់សេដ្ឋកិច្ចពិសេស

SEZs បានចូលរួមចំណែកដល់ការអភិវឌ្ឍជាតិច្រើនណាស់ និងលើសពីគោលដៅបឋម ផ្នែកគោលនយោបាយទៅទៀត។ ការចូលរួមចំណែកទាំងនេះ អាចបែងចែកជាប្រភេទ ឋិតិវន្ត (static) និង ថាមវន្ត (dynamic)។ ការចូលរួមចំណែកឋិតិវន្តរួមមាន វិនិយោគផ្ទាល់ពីបរទេស(FDI) ការមានការងារធ្វើ និងកំណើនការនាំចេញ។ ការចូលរួមចំណែកថាមវន្ត រួមមាន ការបង្កើនកម្រិតជំនាញ ការផ្ទេរបច្ចេកវិទ្យា ពិពិធកម្មការនាំចេញ ការកែលំអប្រសិទ្ធភាពធ្វើជំនួញនៃសហគ្រាសក្នុងស្រុក ការបង្កើតកញ្ចុំឧស្សាហកម្ម និងការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល។ ប៉ុន្តែមានភស្តុតាងបង្ហាញថា ការចូលរួមចំណែករបស់ SEZs ប្រែប្រួលខុសគ្នាពី ប្រទេសមួយទៅប្រទេសមួយ ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ។ Warr and Menon (2015) បានបែងចែក លក្ខណៈសំគាល់ និងផលប៉ះពាល់នៃ SEZs ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ ដូចមានក្នុងតារាង២។

## លទ្ធផល និងបញ្ហាប្រឈមនៃតំបន់សេដ្ឋកិច្ចពិសេស

SEZs ជាច្រើនទទួលជោគជ័យ ប៉ុន្តែមានច្រើនទៀតមិនបានសម្រេចតាមគោលដៅ ផ្នែកគោលនយោបាយរបស់ខ្លួនទេ ដូចជា នៅឥណ្ឌា SEZs ខ្លះមានជោគជ័យ និងខ្លះទៀតទទួលបរាជ័យ។ ការស្រាវជ្រាវជាក់ស្តែងបង្ហាញថា SEZs ជាច្រើនមានជោគជ័យក្នុងការបង្កើតការងារ និងបង្កើនការនាំចេញ ហើយបង្ហាញលទ្ធផលវិជ្ជមានខ្លះដែរ តាមការវិភាគចំណាយធៀបនឹងផលចំណេញ (Chen 1993; Jayanthakumaran 2004; Monge-González, Rosales-Tijerino and Arce-Alpízar 2005; Warr 1989 cited in Farole and Akinci 2011)។

បទពិសោធន៍សកលលើ SEZs បង្ហាញថា SEZs ដើរតួនាទីសំខាន់ក្នុង កំណើនសេដ្ឋកិច្ច ឧស្សាហូបនីយកម្ម និង ពិពិធភាពសេដ្ឋកិច្ច។ ខ្លាអាស៊ីទាំងបួន (ហុងកុង សិង្ហបុរី កូរ៉េខាងត្បូង និងតៃវ៉ាន់) អាចរក្សាបាននូវអត្រាកំណើនយ៉ាងខ្ពស់ចាប់តាំងពីដើមទសវត្សរ៍១៩៦០ មក ហើយបន្ទាប់មកគឺ ប្រទេសចិនដែលបានស្ទុះឡើង តាំងពីពាក់កណ្តាលទសវត្សរ៍១៩៨០។ ក្នុងប្រទេសទាំងនេះ SEZs បានដើរតួនាទីសំខាន់ក្នុងការបង្កើនគុណភាព និងធ្វើទំនើបកម្មឧស្សាហកម្ម និងក្នុងការរៀបចំឡើងវិញយ៉ាងលឿននូវរចនាសម្ព័ន្ធសេដ្ឋកិច្ច។ នៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង SEZs ជាកត្តាស្នូលជួយជម្រុញកំណើន និងពិពិធកម្មការនាំចេញ។ នៅអាហ្វ្រិក SEZs នៃបណ្តាប្រទេសខាងត្បូងវាលខ្សាច់សាហារ៉ា បានចូលរួមចំណែកយ៉ាងច្រើន ដល់ពិពិធកម្មសេដ្ឋកិច្ច និងឧស្សាហូបនីយកម្មប្រកបដោយជោគជ័យ។ នៅអាមេរិកឡាទីន

ប្រទេស អែលសាល់វ៉ាឌ័រ ហុងឌូរ៉ាស និង សាធារណៈរដ្ឋដូមីនីក បានប្រើ SEZs ដើម្បីរំកិលខ្លួនចេញពីការពឹងផ្អែកលើទំនិញកសិកម្ម ទៅធ្វើកម្មន្តសាលកម្មខ្នាតធំ និងទាញយកចំណេញពីការទទួលបានលក្ខខណ្ឌអនុគ្រោះ ដើម្បីចូលទៅក្នុងទីផ្សារសហរដ្ឋអាមេរិក (Farole and Akinci 2011)។

ទោះយ៉ាងនេះក្តី SEZs ក៏មានចំណុចមិនល្អដែរ។ មានភស្តុតាងបង្ហាញថា ការធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ SEZ ជារឿយៗ វាអស់ច្រើនជាង ផលចំណេញទទួលបាន ដោយសហគ្រាសនានាកេងយកចំណេញពីការលើកទឹកចិត្តនិងបុព្វសិទ្ធិផ្សេងៗដែលមាននៅក្នុង SEZs ទោះបីជាគ្រោងការជាច្រើនមិនបានសម្រេចតាមគោលដៅក្តី (Farole and Akinci 2011)។ SEZs ជាច្រើនសម្រេចបានតែអត្ថប្រយោជន៍បិតិវន្ត ហើយមិនសម្រេចបាននូវអត្ថប្រយោជន៍ថាមវន្តទេ (Kaplinsky 1993)។ អ្នកសិក្សាស្រាវជ្រាវជាច្រើនមើលឃើញ SEZs ថាជា ឧបករណ៍ផ្នែកគោលនយោបាយល្អបំផុតទី២ ឬទី៣ សម្រាប់កែលំអសមត្ថភាពប្រកួតប្រជែង ដោយវែកញែកថា SEZs អាចរីកលូតលាស់តែក្នុងស្ថានភាពជាក់លាក់ខ្លះ និងក្នុងអំឡុងពេលមានកំណត់មួយ (Hamada 1974; Madani 1999; World Bank 1992)។ SEZs អាចទទួលជោគជ័យ លុះត្រាតែមានហេដ្ឋារចនាសម្ព័ន្ធជួយទ្រទ្រង់គ្រប់គ្រាន់ ហើយឥទ្ធិពលនៃការរីកលូតលាស់របស់វា គឺអាស្រ័យលើដំណាក់កាលអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសម្ចាស់ផ្ទះ។

## កត្តាផ្តល់ជោគជ័យសំខាន់ៗ សម្រាប់តំបន់សេដ្ឋកិច្ចពិសេស

មានកត្តាជាច្រើនចូលរួមចំណែកក្នុងជោគជ័យនៃ SEZs ដូចជា ការជម្រះពន្ធគយលឿន បទបញ្ញត្តិធូរស្រាល ការតភ្ជាប់ជាសកលកម្រិតខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធមានកម្រិតអភិវឌ្ឍន៍ខ្ពស់ ភាពសម្បូរកម្លាំងពលកម្មជំនាញនិងពាក់កណ្តាលជំនាញ គ្រឿងលើកទឹកចិត្តផ្តល់ផលចំណេញច្រើន បែបបទការិយាធិបតេយ្យមានតិចបំផុត របបម៉ាក្រូសេដ្ឋកិច្ចបើកចំហ និងគោលនយោបាយផ្នែកពន្ធជាវជួយរក្សាស្ថិរភាពហិរញ្ញវត្ថុ។ បរិយាកាសវិនិយោគក្នុងស្រុកក៏ជះឥទ្ធិពលលើលទ្ធផលSEZsដែរក្នុងនេះការរីកលូតលាស់ជំនួញក្នុងស្រុកយ៉ាងលឿន តែងជួយទាក់ទាញជំនួញ និងវិនិយោគផ្ទាល់ពីបរទេស បានកាន់តែច្រើនទៀត (Aggarwal 2012)។

## បទពិសោធន៍រៀនសូត្របានពីតំបន់សេដ្ឋកិច្ចពិសេសនៅចិន

ប្រទេសចិនបានបង្កើត SEZs ដំបូងៗរបស់ខ្លួនក្នុងទសវត្សរ៍ ១៩៨០ ដើម្បីដកពិសោធន៍ធ្វើកំណែទម្រង់គាំទ្រទីផ្សារសេរី ក្នុងពេលកំពុងអនុវត្តរបបសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំនៅឡើយ។ គោលដៅសំខាន់គឺដើម្បី ធ្វើតេស្តគោលនយោបាយ និងស្ថាប័នថ្មីៗសម្រាប់បម្រើសេដ្ឋកិច្ចទីផ្សារ។ SEZ របស់ក្រុង Shenzhen ទទួលជោគជ័យជាខ្លាំង ហើយ SEZs ក៏បានផុសឡើងទូទាំងប្រទេស។ មានកត្តាជាច្រើនចូលរួមចំណែកក្នុងជោគជ័យនៃ SEZs នៅចិន ដូច Zeng (2010) បានគូសបញ្ជាក់ស្រាប់៖

- ការប្តេជ្ញាចិត្តខ្ពស់ ភាពងាយអនុវត្ត ភាពអាចបត់បែន និងឯករាជ្យភាពនៃអ្នកដឹកនាំកំពូល ផ្តល់នូវស្ថិរភាពកម្រិតខ្ពស់ផ្នែកគោលនយោបាយ និងទំនុកចិត្តដល់វិនិយោគិន នៅតាមកន្លែងត្រូវបង្កើត SEZs។
- វិធីសាស្ត្រមួយជំហានម្តងៗ និងងាយអនុវត្ត គឺមិនមែនកំណែទម្រង់យ៉ាងលឿននោះទេ ដើម្បីជៀសវាងផលវិបាកផ្សេងៗផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដូច Deng Xiaoping បានលើកឡើងក្នុងទស្សនវិជ្ជាកំណែទម្រង់របស់គាត់ថាជា "ការឆ្លងស្ទឹងដោយស្ទាបថ្ម"។
- SEZs នានាតែងមានជាស្រេចនូវ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដ៏ចាំបាច់ៗ ដូចជា ផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី ឧស្ម័ន និងទូរស័ព្ទ ជាដើម ដែលផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការបង្កើតទីផ្សារតាមជំនាញឯកទេស វេទិកាសម្រាប់នវានុវត្តន៍ផ្នែកបច្ចេកវិទ្យា និងមជ្ឈមណ្ឌលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D)។ SEZs ក៏មានសិទ្ធិអំណាចបង្កើតបទបញ្ញត្តិរបស់ខ្លួនផ្ទាល់ ដើម្បីចូលរួមចំណែកញ៉ាំងឲ្យមានការគ្រប់គ្រងអាជីវកម្មប្រកបដោយប្រសិទ្ធភាព។ រដ្ឋាភិបាលបានប្រឹងប្រែងជាខ្លាំង ក្នុងការបង្កើនសមត្ថភាពផ្នែកបច្ចេកវិជ្ជា និងនវានុវត្តន៍ តាមការបង្កើនវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសម្រាប់ R&D និងការផ្តល់គ្រឿងលើកទឹកចិត្តពិសេសៗ ដើម្បីទាក់ទាញក្រុមហ៊ុនប្រើបច្ចេកវិជ្ជាទំនើបៗ និងអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពខ្ពស់ៗ។ ភាពជាដៃគូរវាងវិស័យសាធារណៈនឹងឯកជន រួមទាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនិងមជ្ឈមណ្ឌលសម្រាប់ R&D ផង ក៏ដើរតួនាទីសំខាន់ដែរ។
- ប្រជាជនចិនដែលចេញទៅរស់នៅខាងក្រៅប្រទេស បានចូលរួមចំណែកគួរឲ្យកត់សំគាល់ដល់ជោគជ័យនៃ SEZs ជាពិសេសតាមរយៈ ការផ្ទេរចំណេះដឹងក្នុងរូបភាពជាជំនាញ និងបច្ចេកវិទ្យា វិនិយោគជាមូលធន និងសហគ្រិនភាព នៅក្នុងទសវត្សរ៍១៩៨០។ នៅពេលនោះ ក្រុងហុងកុង ម៉ាកាវ និងតៃវ៉ាន់ កំពុងត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការផ្លាស់ប្តូរទីតាំងមូលដ្ឋានផលិតកម្មកម្មន្តសាល ប្រើពលកម្មច្រើនរបស់ខ្លួន។ ដោយសារ មានភាសានិងវប្បធម៌ស្រដៀងគ្នា និងមានទីតាំងនៅជិតគ្នា វិនិយោគផ្ទាល់ពីបរទេសក៏បានហូរចេញពីតំបន់ទាំងនេះទៅកាន់ SEZs នៅចិន។
- SEZs នៅចិន មានផែនការអភិវឌ្ឍន៍និងគោលដៅច្បាស់លាស់ ដើម្បីចូលរួមចំណែក ជំរុញកំណើន ផសស បង្កើតការងារ ពន្លឿនការនាំចេញ ទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស ព្រមទាំង ទទួលបានចំណូលពន្ធផ្សេងៗ ។ SEZs ទាំងនេះមានការប្រកួតប្រជែងគ្នាជាខ្លាំង ដែលលើកទឹកចិត្តឲ្យសហគ្រាសនានាកាន់តែបង្កើនប្រសិទ្ធភាព និងផលិតភាព។ រដ្ឋាភិបាលធ្វើការត្រួតពិនិត្យ និងតាមដានយ៉ាងជិតដល់នូវ ផែនការអភិវឌ្ឍន៍ គោលដៅ និងការប្រកួតប្រជែង។

## ឯកសារយោង

Aggarwal, Aradhna. 2012. "SEZ-Led Growth in Taiwan, Korea, and India: Implementing a Successful Strategy." *Asian Survey* 52 (5): 872–99. doi:10.1525/as.2012.52.5.872.

Akinci, Gokhan, and James Crittle. 2008. "Special Economic Zone : Performance, Lessons Learned, and Implication for Zone Development." 45869. World Bank. http://documents .worldbank.org/curated/en/343901468330977533/Special-economic-zone-performance-lessons-learned-and-implication-for-zone-development.

Chen, Jinghan. 1993. "Social Cost-Benefit Analysis of China's Shenzhen Special Economic Zone." *Development Policy Review* 11 (3): 261–72. doi:10.1111/j.1467-7679.1993.tb00 041.x.

Farole, Thomas. 2011. *Special Economic Zones in Africa : Comparing Performance and Learning from Global Experience*. World Bank. https://openknowledge.worldbank. org/ handle/10986/2268.

Farole, Thomas, and Gokhan Akinci. 2011. *Special Economic Zones : Progress, Emerging Challenges, and Future Directions*. World Bank. https://openknowledge.worldbank. org/ handle/10986/2341.

Hamada, Koichi. 1974. "An Economic Analysis of the Duty-Free Zone." *Journal of International Economics* 4 (3): 225–41. doi:10.1016/0022-1996(74)90044-0.

Jayanthakumaran, Kankesu. 2004. "Benefit-Cost Appraisals of Export Processing Zones: A Survey of the Literature." https:// papers.ssrn.com/abstract=376569.

Kaplinsky, Raphael. 1993. "Export Processing Zones in the Dominican Republic: Transforming Manufactures into Commodities." *World Development* 21 (11): 1851–65. doi:10.1016/0305-750X(93)90087-P.

Madani, Dorsati. 1999. *A Review of the Role and Impact of Export Processing Zones*. Policy Research Working Papers. World Bank. doi:10.1596/1813-9450-2238.

Monge-González, Ricardo, Julio Rosales-Tijerino and Gilberto Arce-Alpízar. 2005. "Cost-Benefit Analysis of the Free Trade Zone System: The Impact of Foreign Direct Investment in Costa Rica." OAS Trade, Growth and Competitiveness Studies. Washington, DC: Organization of American States Office of Trade, Growth and Competitiveness. http://citeweb. info/20050632506.

Pakdeenurit, P., N. Suthikarnnarunai and W. Rattanawong. 2014. "Special Economic Zone: Facts, Roles, and Opportunities of Investment." Proceedings of the International Multi Conference of Engineers and Computer Scientists 2014 Vol II, 1047–51, Hong Kong, 12–14 Mar 2014.

Shah, Semil. 2008. *Special Economic Zones in South Asia: A Comparative Analysis of Bangladesh, Sri Lanka, and India*. Cambridge, MA: John F. Kennedy School of Government.

Shakya, Mallika. 2009. "Clusters for Competitiveness: A Practical Guide and Policy Implications for Developing Cluster Initiatives." SSRN Scholarly Paper ID 1392479. Rochester, NY: Social Science Research Network. https:// papers.ssrn.com/abstract= 1392479.

Warr, Peter G. 1989. "Export Processing Zones: The Economics of Enclave Manufacturing." *World Bank Research Observer* 4 (1): 65–88.

Warr, Peter, and Jayant Menon. 2015. "Cambodia's Special Economic Zones." Arndt-Corden Department of Economics. https://acde.crawford.anu.edu.au/publication/working-papers-trade-and-development/7804/cambodias-special-economic-zones.

Wong, Kwan-Yiu. 1987. "China's Special Economic Zone Experiment: An Appraisal." Geografiska Annaler. Series B, Human Geography 69 (1): 27–40. doi:10.2307/490409.

World Bank. 1992. "Export Processing Zones." 10500. World Bank. http://documents.worldbank. org/curated/ en/400411468766543358/Export-processing-zones.

Zeng, Douglas Zhihua. 2010. *Building Engines for Growth and Competitiveness in China: Experience with Special Economic Zones and Industrial Clusters*. World Bank. https:// openknowledge.worldbank.org/handle/10986/2501.